# "កសាងឡើងវិញឲ្យកាន់តែប្រសើរ" មានន័យថា ការស្តារឡើងវិញនូវសិទ្ធិសមូហភាពនិងកាតព្វកិច្ចរបស់រដ្ឋ

បណ្ឌិត ហ៊ីដាយ៉ាត ហ្គ្រីនហ្វៀល

IUF អាស៊ី/ប៉ាស៊ីហ្វិក

១៧ សីហា ២០២០

ការរីករាលដាលនៃជំងឺកូវីដ១៩ និងផលប៉ះពាល់ផ្នែកសង្គមនិងសេដ្ឋកិច្ចដ៏ខ្លាំងក្លានេះ បង្ហាញឲ្យឃើញនូវភាពផុយស្រួយនៃប្រព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្ន ដែលជាប្រព័ន្ធមួយដែលផ្តល់អាទិភាពទៅលើប្រាក់ចំណេញឯកជន ជាជាងផ្តល់អាទិភាពទៅលើមនុស្ស ព្រមទាំងផ្តល់បុព្វសិទ្ធិដល់ទ្រព្យសម្បត្តិសាជីវកម្ម ជាជាងសុខភាពសាធារណៈ និងសុខុមាលភាពរបស់សហគមន៍យើង។ ក្នុងរយៈពេលបួនទសវត្សកន្លងមកនេះ ឯកជនភាវូបនីយកម្មទៅលើសេវាសាធារណៈនិងសាធារណៈ ក្រោមរូបភាពធ្វើឲ្យមានប្រសិទ្ធផលនោះ គឺជាការបង្កើតនូវឱកាសបន្ថែមទៀតសម្រាប់ក្រុមហ៊ុនឯកជនធំៗ និងក្រុមហ៊ុនសាជីវកម្មឆ្លងដែន ក្នុងការពង្រីកអាជីវកម្មនិងបង្កើនប្រាក់ចំណេញរបស់ខ្លួន ខណៈដែលរដ្ឋាភិបាល ដកខ្លួនចេញពីកាតព្វកិច្ចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ក្នុងការការពារជីវភាពរស់នៅ សុខភាព និងសុខុមាលភាព របស់ប្រជាជន។ ការងារ កិច្ចគាំពារសង្គម ការថែទាំសុខភាព ការអប់រំ លំនៅដ្ឋាន ចាកចេញពីភាពជាសិទ្ធិ ទៅជាសេចក្តីប្រាថ្នាទៅវិញ។ ឥឡូវនេះ យើងកំពុងតែចំណាយប្រាក់កាស ដើម្បីទទួលបានវា។

ម៉ូដែលនៃកំណើនផ្តោតទៅលើការនាំចេញ ដោយផ្អែកទៅលើការវិនិយោគបរទេស បង្កើតបានជាប្រព័ន្ធសេដ្ឋកិច្ចដែលមានលក្ខណៈផុយស្រួយនិងងាយរងគ្រោះ ដែលមានការបែកខ្ទេច ក្រោយការរាតត្បាតនៃជំងឺបានកើតឡើង តែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ។ សម្រាប់ប្រទេសនៅអាស៊ានភាគច្រើន កំណើនសេដ្ឋកិច្ចដែលកើតមានឡើងតាំងពីចុងវិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ១៩៩៨ នឹងត្រូវបាត់បង់អស់នៅត្រឹមខែកញ្ញា។ នេះមានន័យថា កំណើនរយៈពេលពីទសវត្ស ត្រូវបាត់បង់អស់ត្រឹមតែរយៈពេល៦ខែប៉ុណ្ណោះ។ នេះមិនគ្រាន់តែជាការបង្ហាញថាតើវិបត្តិសេដ្ឋកិច្ច មានសភាពធ្ងន់ធ្ងរយ៉ាងណានោះទេ គឺវាថែមទាំងបង្ហាញឲ្យឃើញ ថាតើកំណើនរយៈពេល២០ឆ្នាំចុងក្រោយនេះ មានភាពរាក់កំភែល មិនស៊ីជម្រៅ យ៉ាងណាខ្លះ។ ទ្រព្យសម្បត្តិរបស់សាជីវកម្មត្រូវបានពង្រីកបន្ថែម ការនាំចេញមានការកើនឡើង ផលិតផលក្នុងស្រុកសរុប (GDP) កើនឡើងខ្លាំង ប៉ុន្តែ ភាពក្រីក្រនិងវិសមភាពក៏មានការកើនឡើងដែរ។ សេវាសាធារណៈ កិច្ចគាំពារសង្គម ការមានការងារអចិន្ត្រៃយ៍ ដែលសុទ្ធតែមានសារៈសំខាន់សម្រាប់ភាពធន់របស់សេដ្ឋកិច្ច បែរជាមានការធ្លាក់ចុះទៅវិញ។ តាមរយៈការធ្វើសេដ្ឋកិច្ចកាន់តែមានលក្ខណៈក្រៅប្រព័ន្ធ វាកាន់តែមានភាពបត់បែនច្រើន ប៉ុន្តែវាកាន់តែ មានភាពផុយស្រួយខ្លាំងដែរ។ ខុសឆ្ងាយពីភាពធន់ដូចឫស្សី ដែលអាចស្រូបយកភាពរន្ធត់និងរេតាមខ្យល់ព្យុះនោះ សេដ្ឋកិច្ចដែលផុយស្រួយ បានបែកខ្ទាត់ខ្ទាយដូចកញ្ចក់។

ការជំរុញមិនឈប់ឈរដើម្បីឲ្យ "មានភាពបត់បែន" ក្នុងរយៈពេលបួនទសវត្សចុងក្រោយនេះ បានវាយបំបាក់ការគាំពារសង្គម និងការគាំពារការងារ ដែលមានសារៈសំខាន់ចាំបាច់សម្រាប់ភាពធន់ផ្នែកសេដ្ឋកិច្ច។ រាជរដ្ឋាភិបាល ប្រើប្រាស់សន្ទស្សន៍ភាពងាយស្រួលក្នុងការធ្វើអាជីវកម្មរបស់ធនាគារពិភពលោក ជាវិធានការវាស់

វែងការរីកចម្រើន។ ការកើនឡើងនៃ**លំដាប់ថ្នាក់សម្រាប់ភាពងាយស្រួលក្នុងការធ្វើអាជីវកម្មនេះ** មានន័យថា ជាការណែនាំឲ្យកាន់តែមានភាពបត់បែន និងការធ្វើនិយ័តកម្មឡើងវិញ ដែលរុញឲ្យអ្នកធ្វើការកាន់តែច្រើន ធ្លាក់ចូលទៅក្នុងសភាពការងារដែលគ្មានសន្តិសុខ (តាមរយៈការធ្វើការងារតាមកិច្ចសន្យា និងការផ្តល់ធនធានពីក្រៅទៅវិញ) ព្រមទាំង កាន់តែកើនឡើងនូវសេដ្ឋកិច្ចក្រៅផ្លូវការដែលគ្មាននិយ័តកម្ម។ ឧទាហរណ៍ ប្រទេសថៃ ត្រូវបានគេយល់ឃើញថា ជាជោគជ័យមួយ នៅពេលដែលប្រទេសនេះ កើនពីលំដាប់៣៤ ទៅ ២១ នៅក្នុងលំដាប់ថ្នាក់នៃ**ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម**។ ប៉ុន្តែ ស្របពេលជាមួយគ្នានេះ អាត្រាភាពក្រីក្រកើតឡើងដល់១០% ដោយមានមនុស្ស ២លាននាក់ផ្សេងទៀត ត្រូវបានធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ កាន់តែសំខាន់នោះ គឺការដែលមនុស្សក្នុងលំដាប់ក្រោមបំផុតចំនួន ៤០% នៃរបាយប្រាក់ចំណូល នៅក្នុងប្រទេសថៃ ទទួលបានប្រាក់ឈ្នួលធ្លាក់ចុះ និងប្រាក់ចំណូលធ្លាក់ចុះ។ ហើយរឿងនេះ បានកើតឡើងតាំងពីមុនការរាតត្បាតនិងវិបត្តិដោយសារជំងឺកូវីដ១៩ មកម្ល៉េះ។

ដើម្បី "**កសាងឡើងវិញឲ្យកាន់តែប្រសើរ**" យើងត្រូវការស្តារអ្វីៗឡើងវិញដែលត្រូវបានដួលរលំ និងត្រូវបានបោះបង់ចោល ដោយសារតែ ភាពបត់បែន។ យើងត្រូវការធ្វើជាតិតូបនីយកម្មទៅលើឧស្សាហកម្មនិងសេវាកម្មសំខាន់ៗ ដោយរាប់បញ្ចូលទាំង សុខាភិបាល ថាមពល ទឹក ការដឹកជញ្ជូន និងស្តារឡើងវិញ ការចំណាយសាធារណៈ ដើម្បីគាំទ្រដល់ការអប់រំ លំនៅដ្ឋាន ម្ហូបចំណីនិងអាហារូបត្ថម្ភ ក៏ដូចជាការគាំពារសង្គម និងការបង្កើតការងារ។ យើងត្រូវការកសាងភាពធន់ក្នុងសេដ្ឋកិច្ច ដែលស៊ីគ្នាទៅនឹងភាពមានធនធានគ្រប់គ្រាន់ និងភាពធន់សម្រាប់សហគមន៍របស់យើង និងដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជន។ យើងត្រូវការ បោះបង់ **ភាពងាយស្រួលក្នុងការធ្វើអាជីវកម្មរបស់ធនាគារពិភពលោក** ជាវិធានការវាស់វែងការរីកចម្រើន ហើយផ្ទុយមកវិញ ត្រូវការអះអាងជាថ្មីម្តងទៀត ទៅលើសិទ្ធិរដ្ឋធម្មនុញ្ញរបស់ប្រជាជន ក្នុងការទទួលបាបនការគាំពារសង្គម សុខុមាលភាពសង្គម និងដើម្បីធានាថា ជីវិតមានតម្លៃសក្តិសមនឹងទទួលបានសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ដើម្បី "**កសាងឡើងវិញឲ្យកាន់តែប្រសើរ**" យើងត្រូវកសាងវាសម្រាប់មនុស្សគ្រប់គ្នា គឺមិនមែនសម្រាប់តែមនុស្សមួយចំនួនតូចដែលមានបុព្វសិទ្ធិឡើយ។ យើងត្រូវការកសាងសេដ្ឋកិច្ចដែលមានចីរភាពផ្នែកអេកូឡូស៊ី ដែលបម្រើដល់ប្រជាជននិងដែលការពារបរិស្ថាន ដែលយើងរស់នៅ។ ដើម្បី "**កសាងឡើងវិញឲ្យកាន់តែប្រសើរ**" យើងត្រូវធ្វើឲ្យបានប្រសើរជាងនេះ។